# អគ្គិសនីកម្ពុជា

# ELECTRICITE DU CAMBODGE

## របាយការណ៍ប្រចាំឆ្នាំ ២០១១



# សេចក្ដីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះ អគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ២០១១ ។ យើងមាន មោទនភាពចំពោះលទ្ធផលដែលអគ្គិសនីកម្ពុជាសម្រេចបានអំឡុងឆ្នាំ២០១១ និងជឿ ជាក់យ៉ាងខ្លាំងថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួន ក្នុងគោលបំណង ដើម្បីឲ្យក្លាយជាក្រុមហ៊ុនឈានមុខគេលើ វិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកសាងទំនាក់ទំនង និងសេវា កម្មល្អ ប្រកបដោយទំនុកចិត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្ដីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យដ៏ធំធេងដែលនិយោជិត និយោជក របស់អគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធិផលជាបន្តបន្ទាប់ប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធិផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្តខ្ញុំផ្ទាល់ ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ ដែលបានបំពេញការងារអស់ពីកម្លាំងកាយ និងកម្លាំងបញ្ញាស្មារតី ដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធិផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

**ឌុន ឈាន**

**ប្រធានក្រុមប្រឹក្សាភិបាល**

## ពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



ខ្ញុំមានមោទនភាព និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១១ ដែលអគ្គិសនីកម្ពុជាទទួលបាន ដោយផ្អែកលើចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ជូនអតិថិជន។

ក្នុងឆ្នាំ២០១១ ការលក់ថាមពលអគ្គិសនីរបស់ EDC បានកើនឡើងដល់ ២,៣៥៣.៥០ GWh ឬ ១៥.៨៥% ច្រើនជាងឆ្នាំមុន ទន្ទឹមនឹងនោះ ការបាត់បង់លើប្រព័ន្ធទាំងមូល បានធ្លាក់ចុះមកនូវត្រឹម ៨.១៨%។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ១,៨៤៦ពាន់លានរៀល ឬ ១៥.៤៦% ច្រើនជាងឆ្នាំមុន។ យើងមាននិយោជិតសរុបចំនួន ២,៧៦០ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ៤១៨,០៦៦។

ការសាងសង់ក្នុងឆ្នាំ២០១១សំខាន់ៗ មានបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តតាកែវ ទៅខេត្តកំពត ស្ថិតក្រោមប្រាក់កម្ចីអាឡឺម៉ង់ ដែលមានប្រវែង ៧៣ km និងគម្រោងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីរោងចក្រវារីអគ្គិសនីកំចាយទៅកំពត មានប្រវែង ១១ km និងការសាងសង់អនុស្ថានីយ៍កំពត បានត្រូវបញ្ចប់ និងដាក់ឲ្យដំណើរការ។ បន្ថែមពីនេះទៀត រោងចក្រវារីអគ្គិសនីកំចាយកំលាំង ១៩៣.២ MW ត្រូវបានសាងសង់រួចរាល់ជាស្ថាពរ និងដាក់ឲ្យដំណើរការ និងផ្គត់ផ្គង់ថាមពលទៅបណ្តាញជាតិ តាមរយៈខ្សែបញ្ជូនខាងលើ។

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីរាជធានីភ្នំពេញ ទៅខេត្តបាត់ដំបង ក្រោមរូបភាពជាគម្រោងសាងសង់ ដំណើរការ និងផ្ទេរ (BOT) ដែលមានប្រវែង ៣០០ km ត្រូវបានសាងសង់ជិតរួចរាល់ហើយ រីឯការសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តកំពត ទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការណ៍អន្តរជាតិជប៉ុន (JICA) មានប្រវែង ៨៨ km បាននឹងកំពុងស្ថិតក្រោមការសាងសង់ ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០១២ ។ នៅពេលដែលគម្រោងទាំងនោះត្រូវបានបញ្ចប់ បណ្តាញជាតិនឹងត្រូវពង្រីកវិសាលភាពគ្របដណ្តប់ពីរាជធានីភ្នំពេញ ទៅដល់ខេត្តកំពត ព្រះសីហនុ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ហើយនឹងតភ្ជាប់ទៅបណ្តាញខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប។

បន្ថែមពីនេះទៀត គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងបណ្តាញបញ្ជូន ដែលស្ថិតក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក (WB) ដែលមានគោលបំណងផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជននៅជនបទចំនួន ៥០,០០០ តាមរយៈការពង្រីកខ្សែបណ្តាញបញ្ជូនរង ២២ kV ដើម្បីផ្គត់ផ្គង់ អគ្គិសនីជូនប្រជាជននៅតាមជនបទ ដូចជាតំបន់ភាគខាងលិចភ្នំពេញ ខេត្តកំពត ក្រុងព្រះសីហនុ តាកែវ កំពង់ស្ពឺ និងខេត្តបាត់ដំបង ដែលមានប្រវែង ៦១២ km និងតង់ស្យុងទាបប្រវែង ៦៥៦ km ត្រូវបានសាងសង់រួចរាល់ជាស្ថាពរនៅឆ្នាំ ២០១១នេះ និងបានផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជនរហូតដល់ចំនួន ៨៤,៦៥០ ។

ទន្ទឹមនឹងនោះ អគ្គិសនីកម្ពុជា បានដាក់ទុនវិនិយោគគម្រោងខ្សែបញ្ជូនរង ដើម្បីផ្គត់ផ្គង់ក្នុងអគ្គិសនីដល់បណ្តាខេត្តដែលមានសក្តានុពលមួយចំនួន ដូចជា: ពង្រីកខ្សែបណ្តាញបញ្ជូនរង ២២ kV គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ នៅខេត្តបាត់ដំបង ដើម្បីផ្គត់ផ្គង់ថាមពលឲ្យខេត្តពោធិ៍សាត់ ដែលមានប្រវែង ១៥៣ km និងការសាងសង់ខ្សែបញ្ជូនរង ២២ kV មានប្រវែង ២៨ km និងខ្សែបញ្ជូនរង ៣៥ kV មានប្រវែង ៩៥ km ដើម្បីនាំថាមពល ពីប្រទេសវៀតណាម មកផ្គត់ផ្គង់ឲ្យខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ។

បណ្តាអ្នកកាន់អាជ្ញាប័ណ្ណ ធ្វើសេវាចែកចាយអគ្គិសនី (សេវាករ) ចំនួន ៧១ បានចុះកិច្ចព្រមព្រៀងលក់-ទិញថាមពលអគ្គិសនី ជាមួយអគ្គិសនីកម្ពុជា ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់អាជ្ញាប័ណ្ណរបស់ខ្លួន។

ដោយអនុលោមតាមយុទ្ធសាស្ត្រ និងការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គិសនីកម្ពុជា បានទាញយកនូវជំនួយឥតសំណងផ្សេងៗ និងប្រាក់កម្ចី អូស្ត្រាលី(Aus-Aid) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារអ៊ិចស៊ីមប្រទេសចិន (China Exim Bank) ដើម្បីអនុវត្តគម្រោងពង្រីកបណ្តាញ សម្រាប់អគ្គិសនី កម្មជនបទនៅក្នុងតំបន់ជាច្រើននៃព្រះរាជាណាចក្រកម្ពុជា។ គម្រោងទាំងនេះ គឺស្ថិតក្នុងការសិក្សាសមិទ្ធិលទ្ធភាព ហើយនឹងត្រូវអនុវត្តនៅបណ្តាឆ្នាំខាងមុខ។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្តល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់ម៉ឺនគ្រួសារ រួមទាំងការទាក់ទាញការវិនិយោគនៅទូទាំងប្រទេស ដែលប្រការទាំង នេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនឥតឈប់ឈរ ក្នុងការជួយប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំសម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តរភាពសេដ្ឋកិច្ច និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សំគាល់ពីការចូលរួមចំណែក និងការប្តេជ្ញាចិត្តដ៏មុះមុតរបស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ ដែលមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាពនេះ។ យើងខ្ញុំសូមសម្តែងនូវកតញ្ញូដ៏ជ្រាលជ្រៅ ចំពោះការណែនាំដែលមានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងផ្តល់ការគាំទ្រជាគន្លឹះៗ នៅគ្រប់របត់សំខាន់ៗ ទាំងអស់។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណ ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា ។ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយ ជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែក និងការគាំទ្រ ព្រមទាំងជូនចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការណែនាំកន្លងមក ។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ ចំពោះការគាំទ្រពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះដៃគូរអភិវឌ្ឍន៍នានា និងដៃគូអ្នកផលិតថាមពលឯករាជ្យទាំងអស់ ក្នុងការជួយជ្រោមជ្រែង និងសហការគ្នាយ៉ាងជិតស្និទ្ធជាបន្តបន្ទាប់ ។

ដោយទទួលបានសមិទ្ធិផល និងការលើកទឹកចិត្តទាំងនេះ យើងខ្ញុំបានត្រៀមខ្លួន ដើម្បីដឹកនាំអគ្គិសនីកម្ពុជា និងវិស័យថាមពល ឲ្យមានការអភិវឌ្ឍន៍ឈានដល់កម្រិតអតិបរមា ។ យើងខ្ញុំមានសង្ឃឹមដ៏មុតមាំថា នាថ្ងៃអនាគត វិស័យថាមពល នឹងមានសន្ទុះដ៏ប្រសើរបំផុត។



**កែវ រតនៈ**

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនី ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ជូនអតិថិជន។

## ទស្សនវិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ ប្រកបដោយ ស្ថេរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ដែលមានអាជ្ញាប័ណ្ណរបស់ខ្លួន ដោយមានតម្លៃប្រកួតប្រជែង។ បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព និងចូលរួមអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

## តួនាទី និងការទទួលខុសត្រូវ

អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយ ថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ អាជ្ញាប័ណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាព ក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការ ផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី និងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានទំនួលខុសត្រូវលើចំណូល ចំណាយ។

អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍តាមល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ ចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ និងធ្វើឲ្យសម្រេចនូវផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្ម ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងអាជ្ញាប័ណ្ណដែលបានអនុម័តដោយអាជ្ញាធរអគ្គីសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ៖

១ ការផលិត ការបញ្ជូន និងការបែងចែកថាមពលអគ្គិសនី ក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។
២ នាំចូល និងនាំចេញ ថាមពលអគ្គិសនី ជាមួយប្រទេសជិតខាង
៣ សាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនអគ្គិសនីជាតិ ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។
៤ សាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរង ក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។
៥ លក់ថាមពលអគ្គិសនី និងបម្រើសេវាកម្មដែលពាក់ព័ន្ធ
៦ ទិញថាមពល បញ្ជូនថាមពល និងទិញ-លក់ថាមពល រវាងអគ្គិសនីកម្ពុជា និងដៃគូអ្នកផលិតថាមពលឯករាជ្យផ្សេងៗទៀត។

អគ្គិសនីកម្ពុជា មានប្រភពទុនបានមកពី ៖

១ ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា

២ អចលនទ្រព្យនិងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាល ដូចមាននៅក្នុងមាត្រាទី៧ នៃអនុក្រិត លេខ ២៣។

៣ ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា

៤ ការផ្តល់ជំនួយឥតសំណង និងហិរញ្ញប្បទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាបានទទួល ដោយមានការអនុម័តពីរាជរដ្ឋាភិបាល ។

៥ ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាល

## ការវិវត្តន៍របស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់អគ្គិសនី មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩០៦ ។ មុនខែតុលា ឆ្នាំ ១៩៥៨ ថាមពលអគ្គិសនី និងការប្រើប្រាស់សម្រាប់បំភ្លឺផ្សេងៗ នៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣ :

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE
- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI
- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE

ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់ លើកលែងតែខេត្តបាត់ដំបង ដែលខេត្តនេះត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយ ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (CFKE)។

យោងតាមក្រឹត្យលេខ: ៦៦៥-NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរគឺ ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ឈ្មោះថា **អគ្គិសនីកម្ពុជា**។

អំឡុងឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរ ដែលទទួលរងគ្រោះថ្នាក់ដោយសារ ៖ សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧១-១៩៧៥) និងមានភាពចលាចលជាប្រវត្តិសាស្ត្រ អំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយ គ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅទីក្រុងភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ដទៃៗទៀតផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជា ត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលាក្រុងភ្នំពេញ ដោយដាក់ឈ្មោះថា អគ្គិសនីភ្នំពេញ ហើយមានភារៈកិច្ចក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្រុងភ្នំពេញ ទន្ទឹមនឹងនោះ ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។

នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរឈ្មោះជាថ្មីទៅជា អគ្គិសនីកម្ពុជាវិញ។ ក្រោយពីការបោះឆ្នោតសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅទីក្រុងភ្នំពេញ។ ចំណែកឯ អង្គភាពបម្រើសេវាកម្មថាមពលអគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួន នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្ត ប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦/១០ អគ្គិសនីកម្ពុជា បានក្លាយជាក្រុមហ៊ុនស្វយ័ត ទទួលខុសត្រូវមានកំណត់មួយជាកម្មសិទ្ធិរបស់រដ្ឋទាំងមូល មានកាតព្វកិច្ចក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ។ អគ្គិសនីកម្ពុជា ជាស្ថាប័នមួយស្របច្បាប់ ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់ចំណេញ ប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

## រចនាសម្ព័ន្ធគ្រប់គ្រង

ក្នុងនាមនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាម្ចាស់សហកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

ឆ្នាំ២០១១ ក្រុមប្រឹក្សានៃអគ្គិសនីកម្ពុជា មានសមាជិកចំនួន០៧ រូប



**ឯកឧត្តម ទុន លាន**

ប្រធាន

តំណាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល



**ឯកឧត្តម កែវ រតនៈ**

សមាជិក

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា (ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)



**ឯកឧត្តម ចាន់ សុធី**

សមាជិក

តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ហែម ក្រាញ ឫទ្ធី**

សមាជិក

តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី



**លោក ហង់ ឧច**

សមាជិក

តំណាង និយោជិតកម្មករ អគ្គិសនីកម្ពុជា



**លោក គូ ខែមលីន**
សមាជិក
តំណាង ក្រសួងយុត្តិធម៌



**លោកស្រី សុខ សុធាធី**
សមាជិក
តំណាង សភាពាណិជ្ជកម្មកម្ពុជា

## ការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា

អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ដោយមានឋានៈស្មើនឹងរដ្ឋលេខាធិកាក្នុងជួររាជរដ្ឋាភិបាល ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅ រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារ ដោយអគ្គនាយករងចំនួន ០៣ រូប និងនាយក ចំនួន ០៨ រូប ។ ឆ្នាំ២០១១ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖



**ឯកឧត្តម កែម រេតៈ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



**ឯកឧត្តម ចាន់ សុជាទ៉ាត**
អគ្គនាយករង
ផែនការ និងបច្ចេកទេស



**លោក ចឹម អ៊ឹម**
អគ្គនាយករង
ហិរញ្ញកិច្ច-អាជីវកម្ម



**ឯកឧត្តម មេង គន្ធា**
អគ្គនាយករង
រដ្ឋបាល



**បណ្ឌិត ច្រាំង ជលសា**
នាយក ផែនការយុទ្ធសាស្ត្រ និងគម្រោងការ



**កញ្ញា ស៊ិន សុវណ្ណឌី**
នាយិកា ហិរញ្ញកិច្ច-គណនេយ្យ



**លោក លី ធីយ៉ា**
នាយក រដ្ឋបាល



**លោក ទូ សុខុន**
នាយក បញ្ជូនអគ្គិសនី



**លោក រស់ ចិន្ដា**
នាយក ផលិតកម្ម



**លោក ជា ស៊ីនហើល**
នាយក អាជីវកម្ម-ចែកចាយ



**លោក ខ៉ែម សុខន**
នាយក លទ្ធកម្ម



**លោក អ៊ុំ ពិសិដ្ឋ**
នាយក វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនីកម្ពុជា

# អង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



## ការអភិវឌ្ឍន៍ធនធានមនុស្ស

នៅឆ្នាំ២០១១ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនីកម្ពុជា បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិតមកពីនាយកដ្ឋាន និងអង្គភាពអគ្គិសនីខេត្ត-ក្រុងចំនួន ៥៧៧នាក់ លើវគ្គជំនាញចំនួន ៨៧ មុខវិជ្ជា។ សិក្ខាកាមទាំងនោះ ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមាន៖ សិក្ខាកាម ២០៧ នាក់ ខាងផ្នែកបណ្តាញចែកចាយ សិក្ខាកាម ៥២ នាក់ ខាងផ្នែកប្រព័ន្ធការពាររោងចក្រផលិតអគ្គិសនី សិក្ខាកាម ១០៧ នាក់ ខាងផ្នែកនាឡិកាស្ទង់ សិក្ខាកាម ១៤២ នាក់ ខាងផ្នែកសុវត្ថិភាពពលកម្ម សិក្ខាកាម ៤៥ នាក់ ខាងផ្នែក ផលិតថាមពល និងសិក្ខាកាម ២៤ នាក់ ខាងផ្នែកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់។

អគ្គិសនីកម្ពុជា ក៏បានសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដ៏ទៃទៀត ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលវិស័យថាមពលអគ្គិសនី ដើម្បីបង្កើនចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន។

### តារាងទី ១ : បុគ្គលិកអគ្គិសនីកម្ពុជា ពីឆ្នាំ ២០០៦ - ២០១១

| ប្រភេទ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| បណ្ឌិត | ១ | ១ | ១ | ១ | ១ | ២ |
| អនុបណ្ឌិត | ៦២ | ៧១ | ៨៥ | ៩១ | ១០៤ | ១១៩ |
| វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ | ៣៤៣ | ៣៨១ | ៣៩០ | ៤៤៦ | ៥៥១ | ៦៧២ |
| បច្ចេកទេសជំនាញ | ៣៤៤ | ៣២៦ | ៣៥១ | ៣៥៨ | ៣៩០ | ៤២៩ |
| កម្មករជំនាញ | ២៧៣ | ២៦០ | ២៤៧ | ២៤៥ | ២៤៦ | ២០៧ |
| ទុតិយភូមិ និង គ្មានជំនាញ | ១,១៩១ | ១,១៨០ | ១,១៦៧ | ១,២១៩ | ១,២៧៨ | ១,៣៣១ |
| សរុប | ២,២១៤ | ២,២១៩ | ២,២៤១ | ២,៣៦០ | ២,៥៧០ | ២,៧៦០ |

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា សម្រាប់និយោជិតរបស់ខ្លួន គឺមានដូចខាងក្រោម ៖

- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន មានឱកាស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយផ្តោតលើសមត្ថភាពការងារ ភាពសុចរិត និងភាពស្មោះត្រង់ចំពោះអគ្គិសនីកម្ពុជា។
- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន នូវស្ថានភាពជីវភាពរស់នៅបានល្អ និងសមរម្យ
- ធានានូវភាពត្រឹមត្រូវ ស្មើភាព និងផ្តល់ឱកាសដល់និយោជិតទាំងឡាយ ដើម្បីទទួលបាននូវការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍អគ្គិសនីកម្ពុជា។
- ផ្តល់ជូននូវលក្ខខ័ណ្ឌការងារល្អសមរម្យ ដោយបើកទូលាយក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន ប្រកបដោយភាពស្មោះត្រង់ ក្នុងចំណោមនិយោជិតទាំងអស់ និងជួយជំរុញលើការចូលរួមធ្វើការជាក្រុមក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ ដោយផ្តោតលើទិសដៅស្ថាបនាក្រុមហ៊ុនឲ្យមានការរីកចម្រើន។

## តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងតំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា

តំបន់ដែលគ្រប់គ្រងដោយអគ្គិសនីកម្ពុជា នៅឆ្នាំ២០១១ មានចំនួន ១៥ តំបន់ ដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេងៗ ដូចមានខាងក្រោម៖

### អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ)

**ភ្នំពេញ** គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងរបាយការណ៍នេះ ប្រព័ន្ធអគ្គិសនីភ្នំពេញផ្គត់ផ្គង់ពីអនុស្ថានីយ៍ GS1, GS2, GS3, GS4 ដែលស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញ រួមមាន រាជធានីភ្នំពេញ តំបន់ជាយក្រុង ជុំវិញក្រុងភ្នំពេញ និងមានក្នុងទីប្រជុំជនខេត្តកណ្តាល។

ប្រព័ន្ធអគ្គិសនីភ្នំពេញ ត្រូវបានផ្គត់ផ្គង់ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ (EDC) រោងចក្រផលិតថាមពលឯករាជ្យ (IPPs) ហើយនឹងថាមពលអគ្គិសនីនាំចូលពីប្រទេសវៀតណាម។ អានុភាពតម្លើងរបស់អគ្គិសនីកម្ពុជា (EDC) គឺមាន ៩៤.០០ MW ពីរោងចក្រផលិតថាមពលឯករាជ្យ (IPPs) គឺ ១៨៥.៤៨ MW និងថាមពលនាំចូលពីប្រទេសវៀតណាម មានប្រមាណ ១៣៥ MW ។ រោងចក្រអគ្គិសនីទាំងអស់មានទីតាំងស្ថិតនៅក្នុងក្រុង លើកលែងតែរោងចក្រវារីអគ្គិសនីគីរីរម្យ មានអានុភាពតម្លើង ១២ MW ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ប្រមាណ ១១០ km ពីរាជធានីភ្នំពេញ។

នៅឆ្នាំ២០១១ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញគឺ ៣៩៩.៩០ MW ។ ការផ្គត់ផ្គង់ថាមពលពីការផលិតដោយរោងចក្រអគ្គិសនី និងការនាំចូលមកប្រព័ន្ធអគ្គិសនីភ្នំពេញ បានកើនឡើងពី ១,៦៩៩.៨៦ GWh នៅឆ្នាំ ២០១០ ទៅ ១,៩១៨.៥២ GWh នៅឆ្នាំ២០១១ ហើយការបាត់បង់ថាមពលនៅលើប្រព័ន្ធបានថយចុះពី ៩.៣៩ % នៅឆ្នាំ២០១០ ទៅ ៨.៦៦ % នៅឆ្នាំ២០១១។

**អគ្គិសនីសៀមរាប** សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប បានមកពីការផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងនាំចូលថាមពលពីប្រទេសថៃឡង់ដ៍។

ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ ២០១១ មានលទ្ធភាពផ្គត់ផ្គង់ ៥០.៥០ MW និងតម្រូវការប្រើប្រាស់ អានុភាពជាអតិបរមា ៣៩.០៧ MW ។ ប្រភពថាមពលនៅក្នុងប្រព័ន្ធទាំងមូល ទទួលបានពីការនាំចូលពីប្រទេសថៃឡង់ដ៍តាមរយៈអនុស្ថានីយ៍ ១១៥/២២ kV និងការផលិតដោយរោងចក្រផ្ទាល់ខ្លួនសរុបចំនួន ២១៨.១៥ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៦២៦.១០ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ២៦,១៥៦ ។

**អគ្គិសនីក្រុងព្រះសីហនុ** ក្រុងព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីនៅក្រុងព្រះសីហនុ ជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រអគ្គិសនីឯកជន និងរោងចក្រអគ្គិសនីកម្ពុជា ដែលមានអានុភាពសរុប ១៩.៦០ MW ។ នៅឆ្នាំ២០១១ ក្រោមគម្រោងអគ្គិសនីកម្មជនបទ និងបណ្តាញបញ្ជូនប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុ ត្រូវបានភ្ជាប់ និងផ្គត់ផ្គង់មួយផ្នែកពីប្រព័ន្ធអគ្គិសនីកំពត តាមរយៈបណ្តាញ ២២ kV ដែលបាននាំចូលថាមពលពីប្រទេសវៀតណាម ។ ខ្សែបណ្តាញនេះ បានធ្វើឲ្យអគ្គិសនីក្រុងព្រះសីហនុ មានសមត្ថភាពផ្គត់ផ្គង់អគ្គិសនីទៅ អ្នកកាន់អាជ្ញាបណ្ណ័ និងតំបន់ជាច្រើនទៀត នៅក្រុងព្រះសីហនុ។ ថាមពលផលិតសរុបប្រចាំឆ្នាំមាន ៧៦.២២ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦.៤០ MW ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៣២២.៨១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១,៤៧២ ។

**អគ្គិសនីកំពង់ចាម** កំពង់ចាម មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីកំពង់ចាម ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលមួយផ្នែកត្រូវបានផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលឯករាជ្យ និងមួយផ្នែកទៀត ត្រូវបានផ្គត់ផ្គង់ដោយប្រព័ន្ធអគ្គិសនី ដែលនាំចូលថាមពលពីប្រទេសវៀតណាមនៅឆ្នាំ២០១១។ ថាមពលផលិតសរុបប្រចាំឆ្នាំមាន ៣៨.៤៦ GWh អានុភាពតម្លើង ៩.១៨ MW ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៨.៤៥ MW ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ១៩៤.០១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១,៧៣៩។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ១៩៤.០១ km។

**សាខាមេមត់ និងពញាក្រែក** ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្តាញតង់ស្យុងមធ្យមកម្រិត ២២ kV ។ ក្នុងឆ្នាំ២០១១ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុប

ចំនួន ១៩២.៤៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦,៨០៤ និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១០.៤៨ MW ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីទៅតំបន់ទាំងពីរនេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ MW ហើយនៅឆ្នាំ ២០១១ ថាមពល នាំចូលទទួលបាន ៤៣.៥២ GWh។

**អគ្គិសនីបាត់ដំបង** បាត់ដំបងមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូន ១១៥ kV សម្រាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៍ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យ។ ក្រុងបាត់ដំបង បានផ្គត់ផ្គង់ថាមពលពីការនាំចូលពីប្រទេសថៃឡង់ដ៍ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់។ ប្រព័ន្ធអគ្គិសនីបាត់ដំបង មានលទ្ធភាពផ្គត់ផ្គង់ ២៣.២០ MW ដែលមានប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៦៤២.៩០ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣២,៧៥៦ ។ ថាមពលផលិតសរុបប្រចាំឆ្នាំមាន ៦៧.៨៣ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦.៧៧ MW ។

**អគ្គិសនីបន្ទាយមានជ័យ និងសាខាមង្គលបូរី** បន្ទាយមានជ័យមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ អគ្គិសនីបន្ទាយមានជ័យ ត្រូវបានផ្គត់ផ្គង់ថាមពលអគ្គិសនីពីការនាំចូលពីប្រទេសថៃឡង់ដ៍ និងការផលិតថាមពល ពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ។ លទ្ធភាពផ្គត់ផ្គង់របស់ប្រព័ន្ធអគ្គិសនីនេះមាន ២៣.០៨ MW ។ នៅឆ្នាំ ២០១១ ថាមពលផលិតសរុបគឺ ២៨.៣៧ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦.២៨ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៦,០៨៥។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ២២៣.៦០ km ។

**អគ្គិសនីស្ទឹងត្រែង** ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយ និងមានប្រជាជនរស់នៅរង្វើលៗ ឃ្លាតៗពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធអគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ kV តាំងពីឆ្នាំ ២០១០។ លទ្ធភាពផ្គត់ផ្គង់សរុបគឺ ៣.៦៤ MW ( ដែល ១.៦៤ MW ផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ២ MW នាំចូលពីប្រទេសឡាវ ) ប្រវែងខ្សែ បណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ១៣២.៩៤ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣,០៩០ ។ នៅឆ្នាំ២០១១ ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២.៣៧ MW និងថាមពលផលិតសរុប ៦.៦៥ GWh។

**អគ្គិសនីរតនគិរី** រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្តាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ ប្រព័ន្ធអគ្គិសនីរតនគិរី មានអានុភាពតម្លើង ០.៩៦ MW ពីរោងចក្រវារីអគ្គិសនី របស់អគ្គិសនីកម្ពុជាផ្ទាល់ និង ០.៨០MW ពីរោងចក្រផលិតថាមពលឯកជន និង ៧MW នាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរងតង់ស្យុង ៣៥ kV ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ១២៤.៤២ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣,១៩៧។ នៅឆ្នាំ២០១១ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២.២៨ MW និងថាមពលផលិតសរុបប្រចាំឆ្នាំ ៩.៨៧ GWh។

**អគ្គិសនីតាកែវ និងអង្គតាសោម** តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចេញពីប្រទេសវៀតណាម និងអនុស្ថានីយ៍តាកែវ ត្រូវបានដាក់ឲ្យដំណើការនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ អគ្គិសនីតាកែវមានរោងចក្រអគ្គិសនីរបស់ខ្លួនដើម្បីទុកបម្រុង ដោយមានអានុភាពតម្លើង ១.៥៦ MW ។ នៅឆ្នាំ២០១១ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤.៧៣ MW ដែលប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ២៤០.១៤ km ថាមពលផលិតសរុបប្រចាំឆ្នាំ ១៣.១១ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៧,៦៨២ ។

**អគ្គិសនីកំពត** កំពត មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ រោងចក្រអគ្គិសនីកំពត មានអានុភាពតម្លើង ៣.០៨ MW និងនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញតង់ស្យុង ២២ kV ឆ្លងកាត់កំពង់ត្រាច សម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត។ នៅឆ្នាំ២០១១ ថាមពលផលិតដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងការនាំចូលមានចំនួនសរុប ៣២.៧៥ GWh ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥.៤៧ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៧,៧៩៦។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ២៨៩.៨៦ km ។

**សាខាកំពង់ត្រាច** ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាំងពីឆ្នាំ២០០២ ។ នៅឆ្នាំ២០១១ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ MW សម្រាប់ផ្គត់ផ្គង់ខេត្តកំពតទាំងមូល ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៤៥.៤២ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២,៦៧៦ ថាមពលផលិតសរុប ១៤.៩២ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២.៣៨ MW។

**អគ្គិសនីព្រៃវែង** ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍ នៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីក្រុងព្រៃវែង មានអានុភាពតម្លើងសរុប ២.៤៤ MW ដែលបានមកពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញអគ្គិសនី ដែលនាំចូលថាមពលពីប្រទេសវៀតណាម។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ១០០.២៧ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤,៧២៥ និងតម្រូវការអានុភាពអតិបរមា ១.៤៦ MW ។ ថាមពលផលិតនៅឆ្នាំ២០១១ គឺ ៦.៦០ GWh។

**អគ្គិសនីស្វាយរៀង** ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀងត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម និងពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ អានុភាពផលិតសរុប ៨.៣០ MW ។ នៅឆ្នាំ ២០១១ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់គឺ ២៣.៨០ GWh ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥.៤០ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១,៣៩០។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៤០៦.១៧ km ។

**សាខាបាវិត** ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈការនាំចូលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១១ អគ្គិសនីបាវិត មានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១១.២០ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២,៥៦២ ហើយថាមពលនាំចូលមាន ៥៩.៣៥ GWh និងប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៣៩.៦៨ km ។

**អគ្គិសនីមណ្ឌលគិរី** អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ២០១០។ អានុភាពតម្លើង ៣៧០ kW ផលិតដោយរោងចក្រវារីអគ្គិសនី និង ៣០០ kW ផលិតដោយម៉ាស៊ីនឌីយ៉េសែល។ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា នៅឆ្នាំ២០១១ ថាមពលផលិតសរុប ២.៣៤ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ០.៦២ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១,៤៤៤។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៦៤.៤៨ km ។

**សាខាកែវសីមា** អគ្គិសនីកែវសីមា ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពល គឺតាមរយៈការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ចេញតាមកិច្ចសន្យា ០.៣៦ MW។ ថាមពលនាំចូលគឺ ១.០៣ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៩៧៣។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៤៨.០០ km។

**អគ្គិសនីក្រចេះ** អគ្គិសនីក្រចេះ ត្រូវបានគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលឯកជន ដែលមានអានុភាពតម្លើង ២.៧២ MW ។ ស្ថិតក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជា នៅឆ្នាំ២០១១ ថាមពលផលិតប្រចាំឆ្នាំ ២.៣២ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២.០៨ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣,៥៥២។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៤៦.៧៩ km ។

**សាខាស្នួល** ប្រព័ន្ធអគ្គិសនីស្នួល ស្ថិតនៅខេត្តក្រចេះ ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម ដោយមានថាមពលផលិតប្រចាំឆ្នាំ ៤.៦៤ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១,០៥១។

**អគ្គិសនីកំពង់ស្ពឺ** នៅពាក់កណ្តាលឆ្នាំ ២០១១ សាខាកំពង់ស្ពឺ ត្រូវបានបង្កើតជាអង្គភាពខេត្ត ខណៈដែលសាខានេះ កាលពីពេលកន្លងមក បានស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ។ អង្គភាពថ្មីនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងក្រុងកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពលដល់អនុស្ថានីយ៍កំពង់ស្ពឺ។ ថាមពលដែលលក់ប្រចាំឆ្នាំគឺ ១៥.៩៧ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦,២៧៤ ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០.៤ kV មានប្រវែងសរុបចំនួន ៤១៧.៣៣ km ។

## ការនាំចូលអគ្គិសនីតង់ស្យុងខ្ពស់ពីប្រទេសថៃឡង់ដ៍ និងវៀតណាម

អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៍ តាមរយៈខ្សែបណ្តាញតង់ស្យុង ១១៥ kV តាមច្រកអារ៉ាញ់ប្រាថេតប្រទេសថៃឡង់ដ៍ មកខេត្តបន្ទាយមានជ័យនៃប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់ខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តសៀមរាប ចាប់ពីខែវិច្ឆិកា ឆ្នាំ ២០០៧ ។ អំឡុងឆ្នាំ ២០១១ តាមខ្សែបណ្តាញខាងលើ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីបរិមាណ ៣១៥,៧៤៧,១០០ kWh ពីប្រទេសថៃឡង់ដ៍។

ពីប្រទេសវៀតណាម តាមរយៈបណ្តាញខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចំនួន០២ សៀគ្វី អគ្គិសនីកម្ពុជា បាននាំថាមពលមកផ្គត់ផ្គង់នៅខេត្តតាកែវ និងភ្នំពេញ នៅថ្ងៃទី ៣១ ខែ មីនា និងនៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៩ ។ តាមរយៈខ្សែបញ្ជូននេះ នៅឆ្នាំ២០១១ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីមានបរិមាណ ១,១៣៣,៧៩៣,០២៩ kWh។ បណ្តាញខ្សែបញ្ជូននេះ នឹងត្រូវភ្ជាប់ទៅខ្សែបណ្តាញបញ្ជូន និងអនុស្ថានីយ៍មួយចំនួនទៀត ដែលកំពុងស្ថិតក្នុងការសាងសង់ ហើយបណ្តាញខ្សែបញ្ជូនទាំងមូលនេះ នឹងក្លាយទៅជាបណ្តាញជាតិបញ្ជូន។

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញ MW

| ឆ្នាំ | | | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| ភ្នំពេញ | | តម្លើង | ២១៤.៧៨ | ២៦៤.៧៨ | ២៨៧.២៨ | ៤៥៣.៤៨ | ៤២៩.៤៨ | ៤២៩.៤៨ |
| | | បញ្ចេញ | ១៩២.៤០ | ២០០.៤៩ | ២១៧.៤៩ | ៣១៧.៤៩ | ៣១៧.៨៩ | ៣៣២.៨៩ |
| អគ្គិសនីកម្ពុជា | | តម្លើង | ៤៥.៦០ | ៤៥.៦០ | ៤៥.៦០ | ៤៥.៦០ | ៤៤.០០ | ៤៤.០០ |
| | | បញ្ចេញ | ៤២.៦០ | ៤២.៦០ | ៤២.៦០ | ៤២.៦០ | ៤១.០០ | ៤១.០០ |
| CUPL | IPP | តម្លើង | ៣៧.១០ | ៣៧.១០ | ៣៧.១០ | ៣៧.១០ | ៣៧.១០ | ៣៧.១០ |
| | | បញ្ចេញ | ៣១.៩០ | ៣១.៩៩ | ៣១.៩៩ | ៣១.៩៩ | ៣១.៩៩ | ៣១.៩៩ |
| CETIC | IPP | តម្លើង | ១២.០០ | ១២.០០ | ១២.០០ | ១២.០០ | ១២.០០ | ១២.០០ |
| | | បញ្ចេញ | ១១.០០ | ១១.០០ | ១១.០០ | ១១.០០ | ១១.០០ | ១១.០០ |
| KEP | IPP | តម្លើង | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ |
| | | បញ្ចេញ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ |
| CITY Power | IPP | តម្លើង | ៧.៦៨ | ៧.៦៨ | ៧.៦៨ | ៧.៦៨ | ៧.៦៨ | ៧.៦៨ |
| | | បញ្ចេញ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| CEP | IPP | តម្លើង | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ | ៤៩.២០ |
| | | បញ្ចេញ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ | ៤៥.០០ |
| COLBEN | IPP | តម្លើង | ១៤.០០ | ១៤.០០ | ១៤.០០ | ២០.២០ | ២០.២០ | ២០.២០ |
| | | បញ្ចេញ | ១០.០០ | ១០.០០ | ១០.០០ | ១០.០០ | ១០.០០ | ១០.០០ |
| TH | IPP | តម្លើង | - | ១០.០០ | ១០.០០ | ១០.០០ | - | - |
| | | បញ្ចេញ | - | ៨.០០ | ៨.០០ | ៨.០០ | - | - |
| COLBEN PPSEZ | IPP | តម្លើង | - | - | ១២.៤០ | ១២.៤០ | - | - |
| | | បញ្ចេញ | - | - | ១០.០០ | ១០.០០ | - | - |
| Suvannaphum | IPP | តម្លើង | - | - | ១០.១០ | ១០.១០ | ១០.១០ | ១០.១០ |
| | | បញ្ចេញ | - | - | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ |
| West PP (នាំចូល VN) | IMP | PPA | - | - | - | ២០០.០០ | ២០០.០០ | ២០០.០០ |
| | | បញ្ចេញ | - | - | - | ១០០.០០ | ១២០.០០ | ១៣៥.០០ |
| អគ្គិសនី ខេត្ត-ក្រុង | | តម្លើង | ៦៤.១៤ | ១៦៥.៨៨ | ១៥៤.២៤ | ១៦៣.០៤ | ១៧៤.៦៧ | ១៨៧.០៩ |
| | | បញ្ចេញ | ៥៧.៧៦ | ១៥៩.៣៦ | ១៥០.០៦ | ១៥៦.២៦ | ១៦៧.៨៩ | ១៧៨.៩៩ |
| អគ្គិសនី សៀមរាប | IPP | តម្លើង | ៥.៣០ | ៨.៣០ | - | - | - | - |
| | | បញ្ចេញ | ៤.៥០ | ៨.៣០ | - | - | - | - |
| | EDC | តម្លើង | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ |
| | | បញ្ចេញ | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ | ១០.៥០ |
| | IMP | PPA | - | ៤០.០០ | ៤០.០០ | ៤០.០០ | ៤០.០០ | ៤០.០០ |
| | | បញ្ចេញ | - | ៤០.០០ | ៤០.០០ | ៤០.០០ | ៤០.០០ | ៤០.០០ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញ MW (បន្ត)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អគ្គិសនីខេត្តព្រះសីហនុ | EDC | តម្លើង | ៧.៤០ | ៧.៤០ | ៧.៤០ | ៥.៦០ | ៥.៦០ | ៥.៦០ |
| | | បញ្ចេញ | ៦.២០ | ៦.២០ | ៦.២០ | ៥.០០ | ៥.០០ | ៥.០០ |
| | IPP | តម្លើង | - | ៨.០០ | ៨.០០ | ១៥.០០ | ១៥.០០ | ១៥.០០ |
| | | បញ្ចេញ | - | ៧.០០ | ៧.០០ | ១០.០០ | ១០.០០ | ១០.០០ |
| អគ្គិសនីកំពង់ចាម | IPP | តម្លើង | ៣.៤០ | ៣.៤០ | ៧.៦៨ | ៧.៦៨ | ៧.៦៨ | ៧.៦៨ |
| | | បញ្ចេញ | ១.៩០ | ១.៩០ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ |
| | IMP | PPA | - | - | - | - | - | ១.៥០ |
| | | បញ្ចេញ | - | - | - | - | - | ១.៥០ |
| សាខាពញាក្រែក | IMP | PPA | ២.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| | | បញ្ចេញ | ២.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| សាខាមេមត់ | IMP | PPA | ៣.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| | | បញ្ចេញ | ៣.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| អគ្គិសនីតាកែវ | EDC | តម្លើង | ១.៥៦ | ១.៥៦ | ១.៥៦ | ១.៥៦ | ១.៥៦ | ១.៥៦ |
| | | បញ្ចេញ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ |
| | IMP | PPA | - | - | - | ៣.០០ | ៣.០០ | ៨.០០ |
| | | បញ្ចេញ | - | - | - | ៣.០០ | ៣.០០ | ៨.០០ |
| អគ្គិសនីបាត់ដំបង | EDC | តម្លើង | ១.៦០ | ១.៦០ | ១.៦០ | ១.៦០ | ៣.២០ | ៣.២០ |
| | | បញ្ចេញ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ | ២.៤០ | ២.៤០ |
| | IPP | តម្លើង | ៧.១២ | ៧.៦២ | - | - | - | - |
| | | បញ្ចេញ | ៥.៧០ | ៦.១០ | - | - | - | - |
| | IMP | PPA | - | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ |
| | | បញ្ចេញ | - | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ |
| អគ្គិសនីកំពត | EDC | តម្លើង | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ |
| | | បញ្ចេញ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ |
| | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | IMP | PPA | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| សាខាកំពង់ត្រាច | IMP | PPA | ១.០០ | ៣.០០ | ៣.០០ | ៣.០០ | ១០.០០ | ១០.០០ |
| | | បញ្ចេញ | ១.០០ | ៣.០០ | ៣.០០ | ៣.០០ | ១០.០០ | ១០.០០ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញ MW (បន្ត)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អគ្គិសនីព្រៃវែង | EDC | តម្លើង | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ |
| | | បញ្ចេញ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ |
| | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | IMP | តម្លើង | - | - | - | ០.៨០ | ០.៨០ | ០.៨០ |
| | | បញ្ចេញ | - | - | - | ០.៨០ | ០.៨០ | ០.៨០ |
| អគ្គិសនីបន្ទាយមានជ័យ | EDC | តម្លើង | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ | ៣.០៨ |
| | | បញ្ចេញ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ | ៣.០០ |
| | IMP | PPA | - | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ |
| | | បញ្ចេញ | - | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ | ២០.០០ |
| អគ្គិសនីស្ទឹងត្រែង | EDC | តម្លើង | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ | ១.៦៤ |
| | | បញ្ចេញ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ | ១.៥០ |
| | IMP | PPA | - | - | - | - | ២.០០ | ២.០០ |
| | | បញ្ចេញ | - | - | - | - | ២.០០ | ២.០០ |
| អគ្គិសនីរតនគិរី | IPP | តម្លើង | ០.៥៦ | ០.៨០ | ០.៨០ | ១.៦០ | ១.៦០ | ០.៨០ |
| | | បញ្ចេញ | ០.៤០ | ០.៨០ | ០.៨០ | ១.៤០ | ១.៤០ | ០.៨០ |
| | EDC | តម្លើង | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ |
| | | បញ្ចេញ | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ | ០.៩៦ |
| | IMP | PPA | - | - | - | - | - | ៧.០០ |
| | | បញ្ចេញ | - | - | - | - | - | ៧.០០ |
| អគ្គិសនីស្វាយរៀង | EDC | តម្លើង | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ |
| | | បញ្ចេញ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ | ០.៨០ |
| | IMP | PPA | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ |
| | | បញ្ចេញ | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ | ៧.៥០ |
| សាខាបាវិត | IMP | PPA | ២.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| | | បញ្ចេញ | ២.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ | ៥.០០ |
| អគ្គិសនីមណ្ឌលគិរី សាខាកែវសីមា | EDC | តម្លើង | - | - | - | - | ០.៦៧ | ០.៦៧ |
| | | បញ្ចេញ | - | - | - | - | ០.៦៧ | ០.៦៧ |
| | IMP | PPA | - | - | - | - | ០.៣៦ | ០.៣៦ |
| | | បញ្ចេញ | - | - | - | - | ០.៣៦ | ០.៣៦ |
| អគ្គិសនីក្រចេះ | IPP | តម្លើង | - | - | - | - | - | ២.៧២ |
| | | បញ្ចេញ | - | - | - | - | - | ១.២០ |
| សាខាស្នួល | IMP | PPA | - | - | - | - | - | ១.០០ |
| | | បញ្ចេញ | - | - | - | - | - | ១.០០ |
| សរុប | | តម្លើង | ២៧៨.៩២ | ៣៩០.៦៦ | ៤០១.៥២ | ៦១៦.៥២ | ៦០៤.១៥ | ៦១៦.៥៧ |
| | | បញ្ចេញ | ២៥០.១៦ | ៣៥៩.៨៥ | ៣៦៧.៥៥ | ៤៧៣.៧៥ | ៤៨៥.៧៨ | ៥១១.៨៨ |
| ជាភាគរយ , % | | | ៨៩.៦៩% | ៩២.១១% | ៩១.៥៤% | ៧៦.៨៤% | ៨០.៤១% | ៨៣.០២% |




**រូបភាពទី ១ : អានុភាពតម្លើងនៅឆ្នាំ ២០១១**




**រូបភាពទី ២ : អានុភាពបញ្ចេញនៅឆ្នាំ ២០១១**

**តារាងទី ៣ : ថាមពលផលិត** (GWh)

| ឆ្នាំ / ទីតាំង | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| **ភ្នំពេញ** | **៩០៦.៧៤** | **១,១០៩.៥៥** | **១,២៧៥.៨០** | **១,៣៧៥.៩៤** | **១,៦៩៩.៨៦** | **១,៩១៨.៥២** |
| អគ្គិសនីកម្ពុជា | ១១៣.៦ | ៩៨.៩ | ១៤៣.៨៥ | ៨២.៨៦១ | ៣៣.០៨ | ៤៨.៥២ |
| CUPL | ២៦០.៧៥ | ២៥៨.៤៩ | ២៥៨.៧១ | ១៨២.២២ | ១២០.២១ | ១៣៣.៤១ |
| Jupiter | ៤៩.០៨ | - | - | - | - | - |
| CETIC | ៤៧.៦៩ | ៤៦.៥៣ | ៤៣.៣២ | ៤៤.៤១ | ២៤.២១ | ៣៨.២៥ |
| T.H | - | ១៤.៧ | ៣៤.៥ | ១៧.៣១ | - | - |
| KEP | ២២៣.៩៨ | ២៧៧.៩៩ | ៣១៧.៨៥ | ២៥៦.២៥ | ២៣០.៣៨ | ២៣១.៩០ |
| City Power | ៣៦.១៦ | ៣៨.២៤ | ៤១.៨២ | ៣៤.១១ | ១៨.២៣ | ២៥.២៦ |
| CEP | ១៦៦.០១ | ៣១៥.៥៥ | ៣២៥.៨៨ | ២៦៩.៤៨ | ២៤៧.២៩ | ២២៧.៧០ |
| COLBEN | ៧.៨ | ៥៤.០២ | ៤៦.៤៥ | ៥៣.២៤ | ៣៥.៨០ | ៣៤.១៧ |
| S.L Garment | ១.៦៧ | ៥.១៣ | ៤.៤១ | ៥.៧៦ | ៤.០៥ | ១១.៨៦ |
| COLBEN PPSEZ | - | - | ៣៥.៦៦ | ៤៥.០៦ | - | - |
| Suvannaphum | - | - | ២៣.៣៦ | ២៨.០៣ | ៣២.០៧ | ៤៦.៥០ |
| វៀតណាម | - | - | - | ៣៥៧.២១ | ៩៥៤.៥៥ | ១,១២០.៩៦ |
| **អគ្គិសនីខេត្ត-ក្រុង** | **១៩៩.៧៥** | **២៦៨.៥៦** | **៣៤៩.៦២** | **៤៤១.៩៣** | **៥៤២.៦៣** | **៦៤៥.៥៥** |
| សៀមរាប | ៧៥.៣២ | ១០០.៥៨ | ១៣៦.៩០ | ១៦៥.២០ | ១៩៣.៩៨ | ២១៤.១៥ |
| ព្រះសីហនុ | ៣០.៤៣ | ៣៧.៦២ | ៤៦.៧៣ | ៥១.១៦ | ៦៤.៩៦ | ៧៦.២២ |
| កំពង់ចាម | ១០.១៨ | ១១.៦៥ | ១៥.៥៤ | ២៥.២៧ | ៣៨.៩៥ | ៣៨.៤៦ |
| ពញាក្រែក | ១១.៨៨ | ១៦.៥៦ | ១៨.៣៧ | ២៦.៩២ | ២៥.៩៨ | ៣២.២៧ |
| មេមត់ | ១១.៨៥ | ១២.៦០ | ៩.១៩ | ១០.៥៦ | ១០.៤០ | ១១.២៦ |
| តាកែវ | ៣.៥៩ | ៤.៣៨ | ៥.៧៥ | ៧.៣៩ | ៩.២៨ | ១៣.១១ |
| បាត់ដំបង | ២១.៥៣ | ២៤.៦៦ | ៣២.២៦ | ៣៨.២៥ | ៤៩.៧៣ | ៦៧.៨៣ |
| កំពត | ៤.៨៨ | ៥.៦២ | ៧.៨០ | ១០.១៧ | ២០.៨២ | ៣២.៧៥ |
| កំពង់ត្រាច | ១.៣៦ | ២.១៤ | ៣.៩១ | ៥.៣៩ | ៨.៦៨ | ១៤.៩២ |
| ព្រៃវែង | ២.០៧ | ២.៣៥ | ២.៨០ | ៣.៣៦ | ៤.៦៨ | ៦.៦០ |
| បន្ទាយមានជ័យ | ៣.៤៨ | ១០.៣៣ | ១៤.១៨ | ១៩.១៦ | ២៤.៦៣ | ២៨.៣៧ |
| ស្ទឹងត្រែង | ១.៥៨ | ២.៥៦ | ៣.៥៣ | ៤.៣៩ | ៥.៨០ | ៦.៦៥ |
| រតនគិរី | ៤.៧៩ | ៥.០១ | ៥.៧៨ | ៦.៤១ | ៨.១៩ | ៩.៤៧ |
| ស្វាយរៀង | ២.១១ | ៥.៤៤ | ៩.៤៥ | ១២.៩១ | ១៨.១៥ | ២៣.៨០ |
| បាវិត | ១៤.៧ | ២៧.០៧ | ៣៧.៤២ | ៥៥.៣៧ | ៦០.៨៦ | ៥៩.៣៥ |
| មណ្ឌលគិរី | - | - | - | - | ១.១០ | ២.៣៤ |
| កែវសីមា | - | - | - | - | ០.៤៥ | ១.០៣ |
| ក្រចេះ | - | - | - | - | - | ២.៣២ |
| ស្ទួល | - | - | - | - | - | ៤.៦៤ |
| **សរុប** | **១,១០៦.៤៨** | **១,៣៧៨.១២** | **១,៦២៥.៤២** | **១,៨១៧.៨៧** | **២,២៤២.៤៩** | **២,៥៦៤.០៧** |

